**Ministry of Foreign Affairs and**
**International Cooperation**
**Kingdom of Cambodia**
**OFFICE OF THE SPOKESPERSON**

# បច្ចុប្បន្នភាពស្តីពីស្ថានការណ៍ព្រំដែនកម្ពុជា-ថៃ
# ថ្ងៃទី ៥-៦ ខែតុលា ឆ្នាំ២០២៥

I. លោក អ៊ិន ដារ៉ា ឯកអគ្គរាជទូត និងជាតំណាងអចិន្ត្រៃយ៍កម្ពុជាប្រចាំអង្គការសហប្រជាជាតិ នៅទីក្រុងហ្សឺណែវ បានថ្លែងសុន្ទរកថា នៅថ្ងៃទី ៣ តុលា ឆ្នាំ ២០២៥ ក្នុងសម័យប្រជុំលើកទី ៦០ នៃក្រុមប្រឹក្សាសិទ្ធិមនុស្ស នៅទីក្រុងហ្សឺណែវ។ ក្នុងនោះ បានលើកឡើងអំពីបញ្ហាសិទ្ធិមនុស្ស និងច្បាប់មនុស្សធម៌ ដែលទាក់ទងនឹងស្ថានការណ៍ព្រំដែនរវាងកម្ពុជា និងថៃ។

លោក បានលើកឡើងដោយគូសបញ្ជាក់ថា៖

«កម្ពុជាសូមអរគុណ ចំពោះការអំពាវនាវរបស់ការិយាល័យសម្ព័ន្ធសហប្រជាជាតិដើម្បីសិទ្ធិមនុស្ស (OHCHR) ក្នុងការរក្សាសន្តិភាពឈប់បាញ់ តាមបណ្តោយព្រំដែនរបស់យើង។ សម្រាប់កម្ពុជា សន្តិភាពមិនមែនជាគំនិតអរូបីនោះទេ ប៉ុន្តែជាការតស៊ូប្រចាំថ្ងៃ ដើម្បីការពារសហគមន៍ពីការបង្ខំឱ្យផ្លាស់ទី ដោយការហ៊ុំពទ័្ធយកភូមិ ការរឹបអូសទ្រព្យសម្បត្តិ និងការគំរាមបំភិតបំភ័យបង្ខំឱ្យចាកចេញ។ ការរំលោភបំពានដូចនេះចំពោះសិទ្ធិមនុស្ស និងច្បាប់មនុស្សធម៌ គឺជាអំពើប៉ះពាល់ដ៏ធ្ងន់ធ្ងរ ដល់ដំណើរការផ្សះផ្សា។ ដូច្នេះ ការរក្សាភាពសន្តិភាពឈប់បាញ់ គឺជាការការពារជំហានដំបូងនៃសេចក្តីថ្លៃថ្នូររបស់មនុស្ស ព្រោះសិទ្ធិមនុស្សមិនអាចមានរួចពីសន្តិភាពបានទេ — នៅពេលសន្តិភាពត្រូវបានបំបែក សិទ្ធិមនុស្សក៏ត្រូវបានលុបបំបាត់ផងដែរ»។

II. គិតត្រឹមថ្ងៃទី៦ ខែតុលា ឆ្នាំ២០២៥ ជា**ថ្ងៃទី ៦៩ ហើយ** ដែល**វីរកងទ័ពកម្ពុជាចំនួន ១៨រូប** ត្រូវបានចាប់ឃុំខ្លួនដោយប្រើល្បិចអាក្រក់ពីសំណាក់កងយោធាថៃ ក្រោយបទឈប់បាញ់ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥។ កម្ពុជាសូមឱ្យភាគីថៃ ដោះលែងកងទ័ពកម្ពុជាទាំង ១៨រូប ដោយគ្មានលក្ខខណ្ឌ ប្រកបដោយសុខសុវត្ថិភាព ស្របតាមច្បាប់មនុស្សធម៌អន្តរជាតិ និងគោរពបទឈប់បាញ់ ថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០២៥ អោយបានពេញលេញ។

III. នៅថ្ងៃទី៦ ខែតុលា ឆ្នាំ២០២៥ ក្រុមអ្នកសង្កេតការណ៍អន្តរកាល (IOT) អញ្ជើញចុះពិនិត្យទីតាំងជាក់ស្តែង នៅភូមិជោគជ័យ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ដើម្បីសង្កេតការណ៍ ផ្ទៀងផ្ទាត់ និងរាយការណ៍ នៅស្ថានភាពព្រំដែន ក្រោយបទឈប់បាញ់ចូលជាធរមាន។

IV. នៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៥ **កងទ័ពជើងគោក យោធភូមិភាគទី៥ កម្ពុជា** បានផ្ញើលិខិតឆ្លើយតបទៅនឹងលិខិតរបស់**កងទ័ពភូមិភាគទី១ ថៃ** ដែលមានខ្លឹមសារតម្រូវឱ្យកម្ពុជា **"រៀបចំផែនការជម្លៀសប្រជាជនកម្ពុជា ដែលស្ថិតនៅក្នុងតំបន់ឈមបរិវេណភូមិណងចាន់ ភូមិណងយ៉ាកែវ ស្រុកខូកស្ទឹង ខេត្តស្រះកែវ និងភូមិតាជាក់យ៉ា ស្រុកតា ជាក់យ៉ា ខេត្តស្រះកែវ សរុបចំនួន៣តំបន់ ដោយផ្ញើផែនការជម្លៀសប្រជាជននេះ មកកងទ័ពភូមិភាគទី១ នៅថ្ងៃ ទី៧ ខែតុលា ឆ្នាំ២០២៥សិន"** ទើបភាគីកងទ័ពភូមិភាគទី១ យល់ព្រមចូលរួមកិច្ចប្រជុំ ដែលគ្រោងនឹងធ្វើឡើងនៅថ្ងៃទី១០-១២ ខែតុលា ឆ្នាំ២០២៥។ **កងទ័ពជើងគោក យោធភូមិភាគទី៥ កម្ពុជា** បានបញ្ជាក់នូវគោលជំហរចម្បងៗ ដូចខាងក្រោម —

- ការស្នើប្រជុំគណៈកម្មាធិការព្រំដែនថ្នាក់ភូមិភាគ (RBC) រវាងយោធភូមិភាគទី៥ [កម្ពុជា] និងកងទ័ពភូមិភាគទី១ [ថៃ] គឺជាការអនុវត្តទៅ**តាមស្មារតីនៃការប្រគល់ភារកិច្ចរបស់គណៈកម្មាធិការព្រំដែនទូទៅ GBC នៃប្រទេសទាំងពីរកម្ពុជា-ថៃ** ក៏ដូចជា **ការណ៍ដែលបានកំណត់ក្នុងកិច្ចប្រជុំវិសាមញ្ញលើកទី១ គណៈកម្មាធិការព្រំដែនថ្នាក់ភូមិភាគកម្ពុជា-ថៃ** កាលពីថ្ងៃទី២២ ខែសីហាឆ្នាំ២០២៥។
- ចំពោះ**ករណីភូមិជោគជ័យ និងភូមិព្រៃចាន់ ដែលកងទ័ពភូមិភាគទី១ ថៃ** បានដាក់ស្នើមកយោធភូមិភាគទី៥ កម្ពុជា បានបញ្ជាក់ថា **"គឺត្រូវអនុវត្តទៅតាមអ្វីដែលជាការព្រមព្រៀងគ្នារបស់គណៈកម្មាធិការព្រំដែនទូទៅ GBC នៃប្រទេសទាំងពីរ កាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៥ កន្លងទៅ ពិសេសក្នុងចំណុចទី៨ នៃកំណត់ហេតុកិច្ចប្រជុំដែលបានប្រគល់ភារកិច្ចឱ្យ JBC ដែលជាយន្តការមានសមត្ថកិច្ចក្នុងការប្រជុំដោះស្រាយ។"**
- បញ្ជាក់ថា **RBC មិនមាន [អាណត្តិ ឬ] សមត្ថកិច្ចកំណត់ [ឬកែប្រែ]ខ្សែព្រំដែននោះទេ។**
- ការអង្កេតនៅលើដីជាក់ស្តែង បានបង្ហាញ និងបញ្ជាក់ច្បាស់ថា **"នៅកន្លែងខ្លះក៏មានការកាន់កាប់ និងអាស្រ័យផលជាក់ស្តែងរបស់ប្រជាពលរដ្ឋថៃ ចូលក្នុងអធិបតេយ្យភាពរបស់កម្ពុជាដែរ។** បញ្ហានេះបានបង្ហាញឱ្យឃើញអំពី**ភាពស្មុគស្មាញ និងការលំបាកក្នុងការដោះស្រាយបញ្ហាព្រំដែន** ដែលទាមទារឱ្យមានការគោរពកិច្ចព្រមព្រៀង និងគោលការណ៍ទាំងឡាយដែលភាគីទាំងពីបានឯកភាពគ្នាកន្លងមក។"
- គូសបញ្ជាក់ជាថ្មីអំពីគោលជំហរកម្ពុជា ក្នុងការគោរពទៅតាមអ្វីដែលជាការព្រមព្រៀងគ្នារវាងប្រទេសទាំងពីរ ព្រមទាំង មិនធ្វើសកម្មភាពឯកតោភាគី។
- ចំពោះ**ករណីនៅតំបន់ភូមិជោគជ័យ និងភូមិព្រៃចាន់** រួមទាំងតំបន់ដែលមានសំណង់ថៃ និងប្រជាជនថៃធ្វើសកម្មភាព ហួសបង្គោលព្រំដែនមួយចំនួនផង ត្រូវរង់ចាំលទ្ធផលនៃកិច្ចប្រជុំJBC។
- កម្ពុជា **ជំរុញឱ្យមានកិច្ចប្រជុំ JBC ឱ្យបានឆាប់ដើម្បីស្វែងរកដំណោះស្រាយ [ដោយសន្តិវិធី និងដែលប្រទេសទាំងពីរអាចទទួលយកបាន]៕**

**Ministry of Foreign Affairs and**
**International Cooperation**
**Kingdom of Cambodia**
**OFFICE OF THE SPOKESPERSON**

## Updates on the situation of the Cambodia-Thailand border
## 5-6 October 2025

I. Ambassador and Permanent Representative of Cambodia to the United Nations in Geneva, Mr. In Dara, delivered a statement on October 3, 2025, in the 60th Session of the Human Rights Council in Geneva. The statement addressed human rights and humanitarian law in relation to the border situation between Cambodia and Thailand.

In his remarks, he emphasized:

**"Cambodia appreciates OHCHR's call to uphold the ceasefire along our border. For Cambodia, peace is not an abstract concept but a daily struggle to protect communities from forced displacement, the encirclement of villages, the seizure of property, and threats of eviction. Such violations of human rights and humanitarian law imperil reconciliation. To uphold the ceasefire is, therefore, to defend the fundamental condition of human dignity, for human rights cannot exist apart from peace—when peace is shattered, rights are extinguished."**

II. As of 6 October 2025, it has been 69 days since 18 Cambodian soldiers were captured through bad trick ( deceit ) by the Thai military following the ceasefire agreement of 28 July 2025. Cambodia asks the Thai side to release all 18 Cambodian soldiers unconditionally and safely, in accordance with international humanitarian law and with full respect for the ceasefire of 28 July 2025.

III. On October 6, 2025, the Interim Observer Team ( IOT ) visited **Chouk Chey Village, O' Bei Choan Commune, Ou Chrov District, Banteay Meanchey Province,** in order to observe, verify, monitor and make their report on the border situation after the Ceasefire came into effect.

IV. On October 4, 2025, **the Royal Cambodian Army 5th Military Region** issued a letter in response to **the Thai 1st Army Area** concerning the conditions raised by the Thai side demanding Cambodia to prepare "**an eviction plan for the Cambodian civilians in the contested areas opposite Nong Chan Village, Nong Ya Kaeo Village, Khok Sung District, Sa Kaeo Province, and Ta Phak Ya Village, Ta Phak Ya District, Sa Kaeo Province—a total of three areas— and submits this eviction plan to the 1 Army Area by October 7, 2025**," only then will the 1st Army Area attend the RBC meeting to be held from October 10-12, 2025. The 5th Military Region of Cambodia emphasized its positions as follows—

- The proposal for the RBC meeting between the 5th Military Region and the 1st Army Area is consistent with **the spirit of the outcome of the 1st Special GBC Meeting**, as well as **the outcomes of the First Extraordinary RBC Meeting between the 5th Military Region and the 1st Army Area,** held on August 22, 2025.
- With regard to **the cases of Chok Chey and Prey Chan Villages proposed by the 1st Army Area**, the 5th Military Region underlined that **"the agreement reached at the 1st Special GBC meeting on September 10, 2025 particularly Point 8 of the Agreed Minutes, which recognized the Joint Boundary Commission (JBC) as the mechanism to bring solution to issue related to joint survey and demarcation."**
- Emphasized that **the RBC does not have the mandate or the authority to determine or alter the boundary line.**
- The observations on the ground clearly demonstrated that "**in some areas, there are also occupation and usage by Thai nationals on the land within Cambodian sovereignty.** This situation underscores **the complexity and sensitivity of resolving border issues**, which must be addressed in full respect for the agreements and principles previously established and agreed by both sides."
- Reiterated Cambodia's commitment to upholding the understandings reached between the two countries, including refraining from unilateral actions.

- **The cases of Chok Chey and Prey Chan villages,** including areas where Thai infrastructure has been constructed and Thai nationals are operating beyond existing border pillars, shall await the outcome of the JBC meeting.
- **Called for the convening of the JBC meeting at the earliest possible opportunity to find a peaceful and mutually acceptable solution.**